

# សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង
# ស្តីពី
# “ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម នៅកម្ពុជា ២០២៣-២០៣២ ”

ថ្ងៃពុធ ១០រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣

# មាតិកានុក្រម

សារចនា
សេចក្តីផ្តើម
ស្ថានភាពបច្ចុប្បន្ន
ចក្ខុវិស័យ និងគោលបំណង
ផែនការយុទ្ធសាស្ត្រ ២០២៣-២០៣២
យន្តការអនុវត្ត តាមដាន និងវាយតម្លៃ
សន្និដ្ឋាន

# សាវតា

## 1999-2003

- គណៈកម្មការសិក្សាស្រាវជ្រាវស្តង់ដាគណនេយ្យអន្តរជាតិ
- ច្បាប់ស្តីពីគណនេយ្យសហគ្រាសសវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- ដាក់ឱ្យប្រើស្តង់ដាគណនេយ្យកម្ពុជាចំនួន ១៥ ស្តង់ដា
- ដាក់ឱ្យប្រើស្តង់ដាសវនកម្មកម្ពុជាចំនួន ១០ ស្តង់ដា
- **ក.ជ.គ** និង **វ.គ.ស.ក.** ត្រូវបានបង្កើត

## 2007-2009

- ដាក់ឱ្យប្រើស្តង់ដាគណនេយ្យកម្ពុជាបន្ថែមចំនួន ៣ ស្តង់ដា
- ដាក់ឱ្យប្រើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាចំនួន ២ ស្តង់ដា
- ដាក់ឱ្យអនុវត្តពេញលេញនូវស្តង់ដាគណនេយ្យអន្តរជាតិនៅកម្ពុជា

- CIFRS = IFRS
- CIFRSfor SME= IFRS for SME
- CISA = ISA

## 2010-2016

- ការអនុវត្តស្តង់ដា CIFRS for SME ចូលជាធរមាន
- ការអនុវត្តស្តង់ដា CIFRS ចូលជាធរមាន
- អនុញ្ញាតឱ្យធនាគារ និង MFI ពន្យារការអនុវត្តរហូតដល់ឆ្នាំ២០១៩
- គណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្មត្រូវបានបង្កើតឡើង
- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

## 2021-បច្ចុប្បន្ន

- ការប្រែប្រួលក្របខ័ណ្ឌស្ថាប័ន÷ **ក.ជ.គ.** ប្រែក្លាយជា **ន.គ.ស.** ដោយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។
- **ន.គ.ស.** ជាសេនាធិការឲ្យ **អ.ស.ហ.** និងបន្តអនុវត្តមុខងារភារកិច្ចរបស់ **ក.ជ.គ.** និងមុខងារបន្ថែម ដូចមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្យទៅរបស់អង្គភាពក្រោមឱវាទ **អ.ស.ហ.**។

# សេចក្តីផ្តើម

កម្មវិធីកំណែទម្រង់វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យគណនេយ្យជាឆ្អឹងខ្នងនៃការទ្រទ្រង់ចីរភាពនៃកំណើនតាមរយៈការបង្កើតនូវក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងក្របខ័ណ្ឌស្ថាប័ន សម្រាប់គ្រប់គ្រងដើម្បីបង្កើតនូវប្រព័ន្ធគណនេយ្យរបស់ប្រទេសមួយដែលមានតម្លាភាពនិងភាពអាចទុកចិត្តបាន សម្រាប់ធុរជន វិនិយោគិន និងសាធារណជន។

# ស្ថានភាពបច្ចុប្បន្ន

❖ ចាប់ផ្តើមពីច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ចូលជាធរមាន ក្រុមហ៊ុនផ្តល់សេវាគណនេយ្យនិងសវនកម្ម ចាប់ផ្តើមបង្កើតនិងមានចំនួនច្រើនឡើង



# ស្ថានភាពបច្ចុប្បន្ន

❖ **សមាជិកវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា**

សមាជិកជារូបវន្តបុគ្គល (ខ្មែរ+បរទេស) សរុបចំនួន ១,០១៥ រូប

## ការបណ្តុះបណ្តាលវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

| | | | | |
|---|---|---|---|---|
| អាហារូបករណ៍ ACCA (ក.ស.ហ.វ.) ជំនួយ ADB ÷ឆ្នាំ ២០១៩ ចំនួន ៨៧៥ រូប និងបញ្ចប់ ជោគជ័យ ៨៥ រូប។ | កម្មវិធី ACCA ÷ ត្រឹមខែ មីនា ឆ្នាំ ២០២៣ និស្សិត ខ្មែរ ៣២០ រូប បាន បញ្ចប់ ១២ មុខវិជ្ជា។ | គណនេយ្យករ ជំនាញ (CPA) ÷ និស្សិតខ្មែរ ១០២ រូប បានបញ្ចប់ ដោយជោគជ័យ ។ | កម្មវិធីសិក្សា បច្ចេកទេស គណនេយ្យ÷ ត្រឹម ឆ្នាំ២០២៣ និស្សិត ចំនួន ៥៨៧ រូប កំពុងសិក្សា។ | គណនេយ្យករ ជំនាញអាស៊ាន (ASEAN CPA) ÷ឆ្នាំ ២០២៣ ជនជាតិ ខ្មែរចំនួន ១១ រូប ។ |

# ស្ថានភាពបច្ចុប្បន្ន

## ❖ ស្តង់ដាបច្ចេកទេស

❖ **ឆ្នាំ២០០៣**
÷
- ស្តង់ដាគណនេយ្យ ១៥
- ស្តង់ដាសវនកម្ម ១០

❖ **ឆ្នាំ២០០៧**
÷
- ស្តង់ដាគណនេយ្យ ២០

❖ **ឆ្នាំ២០០៩**
÷
- ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា

❖ **ឆ្នាំ២០១០**
÷
- ស្តង់ដាទាក់ទងនឹងសវនកម្ម
- ស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា

❖ **ឆ្នាំ២០១១**÷ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនមូលប័ត្រជាសាធារណៈ

❖ **ឆ្នាំ២០១៨**
÷ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំនេញ

❖ **ឆ្នាំ២០១៩**
÷ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់

❖ **ឆ្នាំ២០២០**
÷ គោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់

# ស្ថានភាពបច្ចុប្បន្ន

❖ **ក្របខណ្ឌបទប្បញ្ញត្តិ**

ត្រូវបានដាក់ឱ្យអនុវត្ត

*ច្បាប់ចំនួន ៣

*អនុក្រឹត្យ ៣

*ប្រកាសចំនួន ១៣

*សារាចរណែនាំ ៣

*សេចក្តីសម្រេច ២

## ការត្រួតពិនិត្យគុណភាពសវនកម្ម

1. ឆ្នាំ២០១៧៖ ៨ ក្រុមហ៊ុន
2. ឆ្នាំ២០១៨៖ ៩ ក្រុមហ៊ុន
3. ឆ្នាំ២០១៩៖ ១០ ក្រុមហ៊ុន
4. ឆ្នាំ២០២០ ÷ ១១ ក្រុមហ៊ុន
5. ឆ្នាំ២០២១៖ ១៣ ក្រុមហ៊ុន
6. ឆ្នាំ២០២២ ÷១១ក្រុមហ៊ុន

# ស្ថានភាពបច្ចុប្បន្ន




❖ **អនុលោមភាព**

-ឆ្នាំ២០២១÷ សហគ្រាសរងសវនកម្មចំនួន ៨៦៦ ។

-ឆ្នាំ២០២២ ÷សហគ្រាសរងសវនកម្មចំនួន ១,១៤២ និងមិនរងសវនកម្ម ចំនួន ១២,៤៥១ ។

❖ **ការងារប្រព័ន្ធព័ត៌មានវិទ្យា**

**២០១៨**
ប្រព័ន្ធគ្រប់គ្រងការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំនេញ

**២០២២**
ទំនើបកម្មប្រព័ន្ធគ្រប់គ្រងការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំនេញ

**២០២១**
ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី១ ។

**២០២២**
ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី២ ។

**២០២៣**
ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តាមអនឡាញ។

**២០២៣**
ប្រព័ន្ធគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា



# ចក្ខុវិស័យ និងគោលបំណង

❖ **ចក្ខុវិស័យ**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ឆ្នាំ២០២៣- ២០៣២ រៀបចំឡើងជាផែនទីចង្អុលផ្លូវសម្រាប់និយ័តករគណនេយ្យនិងសវនកម្ម ក្នុងការអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួនប្រកបដោយគណនេយ្យភាព និងនិរន្តរភាព នៅប្រទេសកម្ពុជា។

❖ **គោលបំណង**

- ❖ ពង្រឹងការគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មប្រកបដោយដោយប្រសិទ្ធភាព
- ❖ តម្លាភាព គណនេយ្យភាព និង
- ❖ ភាពជឿទុកចិត្តបាននៅព្រះរាជាណាចក្រកម្ពុជា

# ផែនការយុទ្ធសាស្ត្រ ២០២៣-២០៣២

## គោលដៅយុទ្ធសាស្ត្រ

"ប្រព័ន្ធគណនេយ្យនិងសវនកម្មដែលរឹងមាំនិងអាចជឿទុកចិត្តបាន"
ដោយកំណត់នូវសសរស្តម្ភចំនួន ៦ (Pillars) គឺ÷

| សសរស្តម្ភទី១ | សសរស្តម្ភទី២ | សសរស្តម្ភទី៣ | សសរស្តម្ភទី៤ | សសរស្តម្ភទី៥ | សសរស្តម្ភទី៦ |
|---|---|---|---|---|---|
| ការពង្រឹងសមត្ថភាពស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្ម | ការអភិវឌ្ឍធនធានមនុស្សជាគណនេយ្យករដែលមានគុណវុឌ្ឍិ សម្រាប់បំពេញតម្រូវការទីផ្សារ | ការរៀបចំស្តង់ដាបច្ចេកទេស | ការលើកកម្ពស់កម្រិតអនុលោមភាព | ការលើកកម្ពស់គុណភាពសេវា សវនកម្ម | ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគាំទ្របច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល។ |

# សសរស្តម្ភទី១
## ការពង្រឹងសមត្ថភាពស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្ម

### ផែនការរយៈពេលវែង

- (២០២៩-២០៣២)÷បន្តយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងអភិបាលកិច្ចស្ថាប័ន ការកែសម្រួលនិងពង្រឹងការអនុវត្តវិធាននគ្រប់គ្រងផ្ទៃក្នុង, ការពង្រឹងបន្ថែមរចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធលើកទឹកចិត្ត, ការគៀងគរធនធានមនុស្សនិងបន្តការកសាងសមត្ថភាពជំនាញ ការវាយតម្លៃ SOP, ការបន្តពង្រឹងសេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចឌីជីថល និងការពង្រឹងបន្ថែមកិច្ចសហប្រតិបត្តិការ។

### ផែនការរយៈពេលមធ្យម

- (២០២៦-២០២៨)÷បន្តពង្រឹងអភិបាលកិច្ចស្ថាប័ន ការកែសម្រួលនិងពង្រឹងការអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុង, ការពង្រឹងបន្ថែមរចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធលើកទឹកចិត្ត, ការគៀងគរធនធានមនុស្សនិងបន្តការកសាងសមត្ថភាពជំនាញ ការវាយតម្លៃ SOP, ការបន្តពង្រឹងសេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចឌីជីថល និងការពង្រឹងបន្ថែមកិច្ចសហប្រតិបត្តិការ។

### ផែនការរយៈពេលខ្លី

- (២០២៣-២០២៥)÷ពង្រឹងអភិបាលកិច្ចស្ថាប័ន, ការអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុង, រចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធលើកទឹកចិត្ត, ធនធានមនុស្សនិងការកសាងសមត្ថភាពជំនាញ, ទីកន្លែងបំពេញការងារ និងសម្ភារៈបរិក្ខារ, សេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ច ឌីជីថល,កិច្ចសហប្រតិបត្តិការ។

# សសរស្តម្ភទី២

## ការអភិវឌ្ឍធនធានមនុស្សជាគណនេយ្យករដែលមានគុណវុឌ្ឍិ




**- (២០២៩-២០៣២)÷**

-ទិដ្ឋភាពបណ្ឌិតសភា **ន.គ.ស.** និង **វ.គ.ស.ក..** នឹងបន្តសហការគ្នាធ្វើការជាមួយគ្រឹះស្ថានឧត្តមសិក្សា

-ទិដ្ឋភាពវិជ្ជាជីវៈ ការបណ្តុះបណ្តាលកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាក្រៅពីទិដ្ឋភាពវិជ្ជាជីវៈកម្រិតខ្ពស់ **ន.គ.ស.** និង **វ.គ.ស.ក.** នឹងបន្តសហការគ្នាជំរុញការអនុវត្តកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈកម្រិតបឋមនិងមធ្យមនោះគឺកម្មវិធីអ្នកបច្ចេកទេសគណនេយ្យ (Accountant Technician Qualification-ATQ)។

---

**- (២០២៦-២០២៨)÷-**

-ទិដ្ឋភាពបណ្ឌិតសភា **ន.គ.ស.** និង **វ.គ.ស.ក.** នឹងសហការគ្នាបន្តធ្វើការជាមួយគ្រឹះស្ថានឧត្តមសិក្សា

-ទិដ្ឋភាពវិជ្ជាជីវៈ **ន.គ.ស.** និង **វ.គ.ស.ក.** នឹងបន្តសហការគ្នាជំរុញការបណ្តុះបណ្តាលនិងការកសាងធនធានមនុស្ស

---

-**(២០២៣-២០២៥)**÷សហការជាមួយសាកលវិទ្យាល័យនិងគ្រឹះស្ថានឧត្តមសិក្សា, អភិវឌ្ឍន៍ធនធានសាស្ត្រាចារ្យ

# សសរស្តម្ភទី៣
## ការរៀបចំស្តង់ដាបច្ចេកទេស




**-(២០២៩-២០៣២)**÷ រៀបចំនិងដាក់ឱ្យអនុវត្តនូវស្តង់ដាគណនេយ្យផ្ទាល់ខ្លួន លើកលែងតែសហគ្រាសទទួលខុសត្រូវជាសាធារណៈដែលត្រូវបន្តអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងមិនមានការកែសម្រួលស័ម្រាប់ស្តង់ដាសវនកម្ម។

* ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ (វ. សាធារណៈ)

* បច្ចុប្បន្នភាពស្តង់ដាការរាយការណ៍ព័ត៌មានអំពីចីរភាព

**-(២០២៦-២០២៨)**÷ ស្នើកែសម្រួលស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់អនុវត្តឱ្យស្របជាមួយលក្ខខណ្ឌសេដ្ឋកិច្ចនិងធុរកិច្ចនៅកម្ពុជា ពិសេស

* ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

* ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ។

* ពិចារណាដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញ ។

**-(២០២៣-២០២៥)**÷ ស្តង់ដាការរាយការណ៍ព័ត៌មានអំពីចីរភាព, បកប្រែ, បោះពុម្ព និងផ្សព្វផ្សាយស្តង់ដា និងកម្មវិធីសន្ទានុក្រមគណនេយ្យនិងសវនកម្ម

# សសរស្តម្ភទី៤
## ការលើកកម្ពស់កម្រិតអនុលោមភាព




- (២០២៩-២០៣២)៖ បន្តពង្រឹងទាំងកម្រិតអនុលោមភាពគតិយុត្ត (Legal Compliance) និងទាំងកម្រិតអនុលោមភាពបច្ចេកទេស (Technical Compliance)។

- (២០២៦-២០២៨)៖ ពង្រឹងទាំងកម្រិតអនុលោមភាពគតិយុត្ត (Legal Compliance) និងទាំងកម្រិតអនុលោមភាពបច្ចេកទេស (Technical Compliance)។

- (២០២៣-២០២៥)៖ ពង្រឹងកម្រិតអនុលោមភាពគតិយុត្ត (Legal Compliance) និងមិនទាន់គិតដល់កម្រិតអនុលោមភាពបច្ចេកទេស (Technical Compliance) នោះទេ។

# សសរស្តម្ភទី៥
## ការលើកកម្ពស់គុណភាពសេវាសវនកម្ម




- (២០២៩-២០៣២)÷១). បន្តអនុវត្តការចុះត្រួតពិនិត្យគុណភាពសេវាសវនកម្មពេញលេញនិងការអនុវត្តវិធានការរដ្ឋបាលនិងពិន័យ ២). បន្តអភិវឌ្ឍសមត្ថភាពមន្ត្រី និង ៣). បន្តបណ្តុះបណ្តាលសវនករ

-(២០២៦-២០២៨)÷១). ការចាប់ផ្តើមអនុវត្តការចុះត្រួតពិនិត្យគុណភាពសេវាសវនកម្មពេញលេញ និងការអនុវត្តវិធានការរដ្ឋបាលនិងពិន័យ ២). ការអភិវឌ្ឍសមត្ថភាពមន្ត្រីជាការចាំបាច់ ៣). ការបណ្តុះបណ្តាលសវនករក្រោមកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត

-(២០២៣-២០២៥)÷បង្កើតនិងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិនិងវិធានមួយចំនួន រួមមាន ÷ ១). ប្រកាសស្តីពីការត្រួតពិនិត្យគុណភាពសេវាសវនកម្ម, ២). ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈកម្មការត្រួតពិនិត្យគុណភាពសេវាសវនកម្ម, និង៣). វិធានការទណ្ឌកម្មចំពោះក្រុមហ៊ុនសវនកម្ម។

# សសរស្តម្ភទី៦

## ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគាំទ្របច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍សេដ្ឋកិច្ច ឌីជីថល

**ផែនការរយៈពេលវែង**

- (**២០២៩-២០៣២**)

*ការបន្តយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន
*បន្តគាំទ្រ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ
*រៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់
*ការពង្រឹងនិងពង្រីកប្រព័ន្ធបច្ចេកវិទ្យា
*បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗដែលនៅខ្វះចន្លោះ

**ផែនការរយៈពេលមធ្យម**

-(**២០២៦-២០២៨**) ÷បន្តការពង្រឹងសមត្ថភាពស្ថាប័ន បន្តគាំទ្រ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ បន្តសិក្សា និងរៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់បន្តការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ

**ផែនការរយៈពេលខ្លី**

-(**២០២៣-២០២៥**)÷ពង្រឹងសមត្ថភាពស្ថាប័ន ,គាំទ្រ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ សិក្សា និងរៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្ម។

# បញ្ហាប្រឈម

**១).** សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន និងថ្មីៗសង្គ្រាមរវាងអ៊ីស្រាអែល និងក្រុមហាម៉ាស់ ប៉ាឡេស្ទីន

**២).** ការរឹតបណ្តឹងគោល-នយោបាយរូបិយវត្ថុ

**៣).** ការដកចេញនូវវិធានការគាំទ្រជាបន្តបន្ទាប់របស់បណ្តាប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ និង

**៤).** ការថមថយសេដ្ឋកិច្ចជារថនាសម្ព័ន្ធ និងគោលនយោបាយគ្មានកូវីដ-១៩ (Zero-Covid Policy) របស់ប្រទេសចិន។



# យន្តការអនុវត្ត តាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រ

**យន្តការអនុវត្ត៖** ន.គ.ស. បានរៀបចំយុទ្ធសាស្ត្រនេះដោយឈរលើមូលដ្ឋានជាក់ស្តែងនិងប្រាកដនិយម ដោយផ្អែកលើស្ថានភាពនៃការអនុវត្តវិជ្ជាជីវៈនៅកម្ពុជា ការវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍, ធាតុចូលពីវិស័យឯកជននិងស្ថាប័នពាក់ព័ន្ធ និងការសិក្សាដកបទពិសោធន៍ពីបណ្តាប្រទេសក្នុងតំបន់និងលើសកលលោក។

**តាមដាន និងវាយតម្លៃ៖** ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានតួនាទីក្នុងការតាមដាន និងវាយតម្លៃលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដោយយោងតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# សន្និដ្ឋាន

ឯកសារយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលដៅចុងក្រោយ គឺ “**ប្រព័ន្ធគណនេយ្យ និងសវនកម្មដែលរឹងមាំនិងអាចជឿទុកចិត្តបាន**” នៅព្រះរាជាណាចក្រកម្ពុជា ដែលយុទ្ធសាស្រ្តជាអាទិភាពត្រូវបានកំណត់លើ

- ការអភិវឌ្ឍស្ថាប័ននិយ័តករ,
- ការរៀបចំក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនិងវិធានគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម,
- ការបង្កើតយន្តការធានាអនុលោមភាព,
- ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម,
- ការលើកកម្ពស់គុណភាពសេវាសវនកម្ម និង
- ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគាំទ្របច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល

# សូមអរគុណ!

និយ័តករគណនេយ្យនិងសវនកម្ម

# សូមស្វាគមន៍មកកាន់
# បណ្ដាញទំនាក់ទំនងសង្គមផ្លូវការរបស់
# និយ័តករគណនេយ្យនិងសវនកម្ម

Website

Facebook

Telegram

សូមស្កេន QR Code នេះ
ដើម្បីទទួលបានព័ត៌មាន